Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date : 08/12/98 ID no: 100201 ~~F02~~ Team : ____
Latitude : N 12°31'2654" Longitude : E 106°07'5745"
File # 120803A Time 10:30 a.m Location: ________

Site Name : O lorng [Kh] : [illegible] khet : Kratie
srok : Kratie khum : Da phum : Da

| (1. PRISON — circled) | | (2. Burial site — circled) | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | ____ | Pit | ____ | Wat | ____ |
| Previous Prison | ____ | Kiln | ____ | Stupa | ____ |
| Purpose Built | ____ | Rice paddy | ____ | Brick/tile | ____ |
| School | ____ | River/lake | ____ | Wooden | ____ |
| Wat | ____ | Well | ____ | Other | ____ |
| House | ____ | Execution | ____ | | ____ |
| Other | ____ | Other | ____ | | ____ |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
5 Km from National Road #7 from Kratie to Stung Treng. Can not access by car. Have to walk through the forest, rice field and water. Could be lost if you do not have a local person to lead your way.

WITNESS Name Sa Say Age 62 Sex F Address
phum Anchanh khum Da srok Kratie
khet Kratie Identity ________

Estmated number of victim few hundreds Pits execution site Other ____
[according to the witness ____ Report ____ Other ________]
Photos : ________ Roll Number : ________ Shots number ________
Documents: N/A

Interview : ________

Comments: ________

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

also B? see report description

# SITE FORM

Date : 9/12/98 ID no: 100202 Team : ______

Latitude : N 12°29' 40.76" Longitude : E 106°01' 27.89"

File # R120809A Time 4:20 p.m Location: ______

Site Name : Preah Kosamak High School [Kh] : ______ khet : Kratie

srok : Kratie khum : Kratie phum : Kratie

| 1. PRISON | | 2. Burial site | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | | Pit | | Wat | |
| Previous Prison | | Kiln | | Stupa | |
| Purpose Built | | Rice paddy | | Brick/tile | |
| School | ✓ | River/lake | | Wooden | |
| Wat | | Well | | Other | |
| House | | Execution | | | |
| Other | | Other | | | |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:

Just on the left hand side of National Road #7 about 1 km from the provincial town center.

WITNESS: Name Sao Khvich Age 70. Sex M Address

phum Kratie khum Kratie srok Kratie

khet Kratie Identity ______

Estmated number of victim few hundreds Pits execution Other ______

[according to the witness ______ Report ______ Other ______]

Photos : ______ Roll Number : ______ Shots number ______

Documents: N/A

Interview : recorded in cassette tape

Comments: N/A

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

100301

Date : 10/12/98 ID no: ~~100201~~ Team : ____
Latitude : N 12° 20' 4498" Longitude : E 106° 021266"
File # R121001 A Time 8:45 a.m. Location: ____
Site Name : Prek Prasab district office [Kh] : [illegible] khet : Kratie
srok : Prey Prasab khum : Prek Prasab phum : Prek Prasab Kraom

| 1. PRISON (circled) | | 2. Burial site (circled) | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | ____ | Pit | ____ | Wat | ____ |
| Previous Prison | ____ | Kiln | ____ | Stupa | ____ |
| Purpose Built | ____ | Rice paddy | ____ | Brick/tile | ____ |
| School | ____ | River/lake | ____ | Wooden | ____ |
| Wat | ____ | Well | ____ | Other | ____ |
| House | ____ | Execution | ✓ | | ____ |
| Other | ____ | Other | ____ | | ____ |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
Just in front of the current district office. Travel by boat from Kratie town and take about 30 minuts to get to the dock of this district and take a moto taxi to the district office.

WITNESS: Name Phu Vann Than Age 45 Sex M Address
phum ____ khum ____ srok ____
khet ____ Identity Deputy Governor of Prek Prasab district

Estmated number of victim unknown Pits 1 Other ____
[according to the witness ____ Report ____ Other ____]
Photos : ____ Roll Number : ____ Shots number ____
Documents: ____

Interview : Recorded in cassette tape

Comments: This district is 80 Km long lying along the MeKong River. Not many Killing fields in this district because ~~most~~ people here were old people in the KR regime. No Lon Nol administration there as it was a liberation area since 1970.

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

100302

Date: 10/12/98 ID no: ~~100202~~ Team: ____
Latitude: N 12° 16' 2408" Longitude: E 105° 49' 2612"
File # R12/006A Time 1:40pm. Location: ____

Site Name: Wat Chroy Ampil [Kh]: វត្តជ្រោយអំពិល khet: Kratie
srok: Prek Prasab khum: Chambakk phum: Choy Ampil

| 1. PRISON | | 2. Burial site | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | | Pit | | Wat | |
| Previous Prison | | Kiln | | Stupa | |
| Purpose Built | | Rice paddy | | Brick/tile | |
| School | | River/lake | | Wooden | |
| Wat | | Well | ✓ | Other | |
| House | | Execution | ✓ | | |
| Other | | Other | | | |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
It is very difficult to access the site by road and the road is badly damaged and bridges ~~are~~ broken. The only way is going by boat. The ~~old~~ site is 46 Km away from Kratie and 30 Km from Prey Prasab district office. It takes 1:30 mn to get there by speed boat.

WITNESS: Name Kiem Khean Age 83 Sex M Address:
phum Chroy Ampil khum Chambakk srok Prek Prasab
khet Kratie Identity ____

Estmated number of victim 100-150 Pits well Other ____
[according to the witness ____ Report ____ Other ____]
Photos: ____ Roll Number: ____ Shots number ____
Documents: ____

Interview: Recorded in cassette tape.

Comments: ____

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date : 9/12/98 ID no: 100401 Team : ______
Latitude : N 12° 45' 3879" Longitude : E 105° 59' 3112"
File # R1209021A Time 10 a.m. Location: ______

Site Name : Kok Kduoch [Kh] : គោកក្ដួច khet : Kratie
srok : Sambo khum : Sambo phum : Keng Prasat

| 1. PRISON | | 2. Burial site (circled) | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | ______ | Pit | ✓ | Wat | ______ |
| Previous Prison | ______ | Kiln | ______ | Stupa | ______ |
| Purpose Built | ______ | Rice paddy | ______ | Brick/tile | ______ |
| School | ______ | River/lake | ______ | Wooden | ______ |
| Wat | ______ | Well | ______ | Other | ______ |
| House | ______ | Execution | ______ | | ______ |
| Other | ______ | Other | ______ | | ______ |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
2 Km an the right hand side of the lane leading from Kratie provincial town toward Sambo district (if travelling from Kratie toward Sambo). Can not access the site by car. Have to walk through rice-field and accross water (except in dry season Jan. April)

WITNESS: Name Ta Khmaw Age 73 Sex ____ Address:
phum Chamkar Khnong khum Kampong Cham srok Sambo
khet Kratie Identity ______

Estmated number of victim 89 Pits 1 execution site Other ______
[according to the witness ____ Report ____ Other ______ ]
Photos : ______ Roll Number : ______ Shots number ______
Documents: ______

Interview : Recorded in cassette tape.

Comments: Currently ~~[illegible]~~ many ~~[illegible]~~ former prisoners ~~and torturters who were KR security personnel~~ are still alive and live in the same ~~[illegible]~~ sub-district

Documentation Center of Cambodia [DC-Cam]
MAPPING THE KILLING FIELDS OF CAMBODIA, 1997

# SITE FORM

Date : 9/12/98 ID no: 100402 Team : ____
Latitude : N 12° 45' 3538" Longitude : E 105° 55' 2890"
File # R12° 0903 A Time 10:15 a.m. Location: ____

Site Name : Kok Kduoch [Kh] : [Khmer script] khet : Kratie
srok : Sambo khum : Sambo phum : Keng Prasat

| 1. PRISON (circled) | | 2. Burial site | | 3. Memorial | |
|---|---|---|---|---|---|
| Interrogation Ctr. | | Pit | | Wat | |
| Previous Prison | | Kiln | | Stupa | |
| Purpose Built | | Rice paddy | | Brick/tile | |
| School | | River/lake | | Wooden | |
| Wat | | Well | | Other | |
| House | | Execution | | | |
| Other | Forest ✓ | Other | | | |

ACCESSIBILITY DESCRIPTION IN MOST DETAIL AS POSSIBLE:
about 180 m from the execution site

WITNESS: Name Koam UK Age 73 Sex M Address
phum Chamkar Khnong khum Kampong Cham srok Sambo
khet Kratie Identity ____

Estmated number of victim [illegible] Pits ~~execution site~~ Prison Other ____
[according to the witness ____ Report ____ Other ____]
Photos : ____ Roll Number : ____ Shots number ____
Documents: ____

Interview : recorded in cassette tape

Comments: N/A

មជ្ឈមណ្ឌលឯកសារកម្ពុជា

# របាយការណ៍
# ស្តីអំពីការចុះស្រាវជ្រាវគូសផែនទីទាក់ទងអំពើឧក្រិដ្ឋកម្មក្នុងសម័យ
# ប៉ុល ពត ប្រល័យពូជសាសន៍
# នៅខេត្តក្រចេះ

កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩៨ មជ្ឈមណ្ឌលស្រាវជ្រាវឯកសារកម្ពុជា បានចាត់តាំងសហការីរួមមាន ៖

១- លោក **ផាត កុសល** នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា

២- លោក **ស៊ិន ឃិន**

ចុះទៅខេត្តក្រចេះជាលើកទី១ ដើម្បីស្រាវជ្រាវ និងធ្វើផែនទីទាក់ទងអំពើឧក្រិដ្ឋកម្មរបបប្រល័យ ពូជសាសន៍ខ្មែរក្រហម ។

ក្រុមស្រាវជ្រាវបានធ្វើដំណើរចេញទីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩៨ វេលាម៉ោង ៧ព្រឹក ជិះអូប័រតាមដងទន្លេមេគង្គ ទៅដល់ខេត្តក្រចេះនៅវេលាម៉ោង ១៣:០០ ម៉ោង ១រសៀល ។

## ខេត្តក្រចេះ

ក្រុមស្រាវជ្រាវយើងបានជួបលោកស្រីនាយខុទ្ទកាល័យខេត្ត ឈ្មោះ **គ្រឹង ផាវី** និងលោក **អ៊ុច ស៊ុនឡាយ** បច្ចុប្បន្នប្រធានការិយាល័យពត៌មានខេត្តក្រចេះ ។ នៅវេលាម៉ោង ១៤:០០ យើងបានទំនាក់ទំនងការងាររបៀបបទរដ្ឋបាល ជាមួយនោះយើងក៏បានសុំទៅជួបអភិបាលខេត្តរងទី២ ឯកឧត្តម **ប៉ាវ ហមផាន** ។ ប៉ុន្តែមុននឹងជួបលោកអភិបាលខេត្ត យើងបានដឹងពត៌មានប្រយោលពីលោក **អ៊ុច ស៊ុនឡាយ** ជាមន្ត្រីពត៌មានខេត្ត ដែលជាមន្ត្រីចាស់ គាត់បានផ្តល់អោយយើងដឹងជាប្រយោលនូវពត៌មានទីតាំងប្រល័យពូជសាសន៍រួមទូទាំងខេត្តក្រចេះ ។

### ពត៌មានទីតាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

លោក **អ៊ុច ស៊ុនឡាយ** បានអោយយើងដឹងថា ៖

១- ទីតាំងគុកនិងសន្តិសុខ និងទីតាំងពិឃាត ឋិតនៅក្នុងវត្តជ្រោយអំពិល ឋិតក្នុងឃុំសំបុក ស្រុកព្រែកប្រសព្វ ។

២- កោះទ្រាំ ឋិតក្នុងឃុំកោះទ្រាំ ស្រុកក្រចេះ ។

៣- ប្រាំងទន្លេ ឋិតនៅខាងមុខ សាលាស្រុកព្រែកប្រសព្វ ។

៤- គុក និងសន្តិសុខ ការដ្ឋាន អូលង + ខ្វាន់ពីរ-កោះស្រការ ឋិតក្នុងឃុំដា ស្រុកក្រចេះ ។

៥- ស្រុកសំបូរ

ក- កោះសំធំ ការដ្ឋាន

ខ- កោះសំតូច ការដ្ឋាន

គ- គោកក្ដួច Kork Kdauch

ឃ- ភ្នំស្រួច

ង- ប្រស្រាល

ច- អូរ ខ្វាំប៉ែរ

**ស្រុកក្រចេះ**

ក- ល្វេក ឃុំកំពង់ដំរី

ខ- ភ្នំព្រះ

គ- ព្រៃម៉ែសាក់

ឃ- ឃុំដំរីផុង

ទាំងអស់ខាងលើនោះ ជាពត៌មានប្រយោល ដែលក្រុមយើងស្រង់នៅសាលាខេត្ត ពីលោក **អ៊ុច ស៊ុនឡាយ** ប្រធានការិយាល័យពត៌មាន ខេត្តក្រចេះ ។

បន្ទាប់មកទៀត យើងបានទៅជួបឯកឧត្តម **ជៅ ហមជាន** អភិបាលរងទី២ ខេត្តក្រចេះ ។ ក្រុមយើងបានជំរាប អំពីគោលបំណង និងសំណូមពរនៃការចុះមកខេត្តក្រចេះ ។ ហើយសុំអោយលោក បង្កលក្ខណៈច្បាប់ និង សុំអោយលោកជួយចំណារជាលាយលក្ខណ៍អក្សរអោយក្រុមយើងទៅសហការជាមួយមន្ត្រីនានានៅស្នងការប៉ូលីស និងនៅបណ្ដាមន្ទីរជំនាញ ព្រមតាំងលោកអភិបាលស្រុកនានា ទូទាំងខេត្តក្រចេះ ។

នៅទីនោះ យើងបានស្រង់ពត៌មានដូចជា :

**ទីតាំងខេត្តក្រចេះ**

ខេត្តក្រចេះ ឋិតនៅប៉ែកឥសាន នៃប្រទេសកម្ពុជា ចម្ងាយផ្លូវគោក ៣៤០គីឡូម៉ែត្រ ផ្លូវទឹក ២២០គីឡូម៉ែត្រ ពីទីក្រុងភ្នំពេញ ។ សម័យ **ប៉ុល ពត** តំបន់ ៥០៥ ខាងត្បូងទន្លេមេគង្គ តំបន់២០៣

ខាងជើងទន្លេមេគង្គ ។ ខេត្តក្រចេះ ឋិតក្នុងតំបន់ត្រួតត្រារបបខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ ១៩៧៩ រយៈជិត ១០ឆ្នាំ ខុសពីខេត្តនានានៅកម្ពុជា នាសម័យ **ប៉ុល ពត** ។ ជាតំបន់ស្វ័យយ័តរបស់ពួកខ្មែរក្រហម ។

ព្រំប្រទល់ខេត្ត

- ខាងជើង ទល់ខេត្តស្ទឹងត្រែង
- ខាងត្បូង ខេត្តកំពង់ចាម (ប្រទេសវៀតណាម)
- ខាងកើត ខេត្តមណ្ឌលគិរី
- ខាងលិច ខេត្តកំពង់ធំ

ខេត្តក្រចេះមានស្រុក ៥ ចំណុះ គឺ ៖

១- ស្រុកក្រចេះ

២- ស្រុកសំបូរ

៣- ស្រុកព្រែកប្រសព្វ

៤- ស្រុកឆ្លូង

៥- ស្រុកស្នួល

ខេត្តនោះចែកចេញជា ៤០ឃុំ មាន ២៥០ភូមិ មានផ្ទៃដីសរុប ១១.០៩៤គីឡូម៉ែត្រការ៉េ ក្នុងនោះ ផ្ទៃដីបង្កបង្កើនផល ៣៤.៤៩២ហិកតា ផ្ទៃដីព្រៃឈើ ៨៣.៥០៖ និង ០,៥០៖ ដីក្រហម សំរាប់ដំណាំ កៅស៊ូ នៅស្រុកស្នួល ។

ក្របខ័ណ្ឌមន្ត្រីរាជការទូទាំងខេត្ត សរុប ៣.១៨៨នាក់ ស្រី ១.១១៤នាក់ ។

ចំនួនប្រជាជនសរុប៤៩.២១៤ គ្រួសារ មនុស្ស ២៦២.៩៤៤នាក់ ស្រី ១៣៣.០៨៦នាក់ ។ ជនជាតិ ០.៨ ជនជាតិ គឺ ៖

១- ព្នង ស្ទៀង គួយ ខោញ មិល ក្រោល ថ្នូន និង ចាម ។

មុខរបរប្រជាជន ភាគច្រើនស្រែចំការ នេសាទខ្លះ អុស និងកាប់ឈើភាគច្រើន ។

ក្រោយពីបានដឹងពត៌មានពីឯកឧត្តមអភិបាលរងទី២ខេត្តរួច យើងបានទៅទំនាក់ទំនងសុំជួបស្នងការរង ទី១ខេត្ត លោក **ឈួច ណារុង** នៅទីនោះយើងបានស្រង់ពត៌មាន អំពីសភាពការណ៍សន្តិសុខ ទូទាំងខេត្ត រួចហើយក្រុមយើងបានសំណូមពរអោយលោកជួយបង្កលក្ខណៈងាយស្រួល ផ្នែកសន្តិសុខដោយសុំប៉ូលីស ស្រុក ជួយរួមដំណើរចុះទៅទីតាំងប្រល័យពូជសាសន៍ នៅតំបន់ជនបទឆ្ងាយៗពីសាលា ស្រុកនានា ។

ក្រោយពីបានទំនាក់ទំនងមន្ត្រីជាន់ខ្ពស់ខេត្តរួច យើងឆ្លៀតឱកាស ល្ងាចថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៩៨ ថ្ងៃដំបូងចុះទៅជួបសាក្សីមន្ទីរនានា មន្ទីរព័ត៌មានខេត្ត មន្ទីរវប្បធម៌ខេត្ត និងមន្ត្រីចាស់ៗ របស់សិរុខេត្ត ដើម្បីស្រង់ព័ត៌មានបន្ថែមទៀត លទ្ធផលគឺបានឆ្លុះបញ្ចាំងដូចព័ត៌មាន ដែលយើងស្រង់ពីលោក **អ៊ុច ស៊ុនឡាយ** និងរិតតែច្បាស់ទៀត ។ យើងបានជួបសាក្សី ២នាក់ គឺ **ឈ្នោង ជាត** និងលោក **អ៊ុក ច្រឹង** ធ្លាប់ជាប់គុកនៅអូរលង ឃុំដា ស្រុកក្រចេះ បានថតសំភាសន៍ពីលោក **អ៊ុក ច្រឹង** នូវព័ត៌មាន ទាក់ទង ពេលគាត់ជាប់គុក នៅអូរលង ។

សាក្សី ១ **ឈ្នោង ជាត** អាយុ ៥២ឆ្នាំ សព្វថ្ងៃអធិការកិច្ច ខេត្តក្រចេះ

២ **អ៊ុក ច្រឹង** អាយុ ៥០ឆ្នាំ អនុប្រធានការិយាល័យ ព័ត៌មានខេត្ត

ព័ត៌មានជាក់ស្តែងពីសាក្សី ៈ

ព័ត៌មាននៅគុក និងសន្តិសុខ ការដ្ឋាន អូរលង ឃុំដា

សាក្សីធ្លាប់ជាប់គុក គាត់ប្រាប់ថា អ្នកជាប់គុករួមជាមួយគាត់ ប្រហែល ២០០នាក់ អ្នកនៅរស់ ប្រហែល ១០០នាក់ អ្នករស់នៅឆ្នាំ១៩៧៨-៧៩ ពេលរណសិរ្ស **ហេង សំរិន** រំដោះបានខេត្តក្រចេះ ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៧៨ គឺរំដោះមុនថ្ងៃ ៧ មករា ១៩៧៩ ។

ប្រភេទជនរងគ្រោះ ប្រមូលពីបណ្តាឃុំនានា ទូទាំងស្រុកក្រចេះ អ្នកជាប់និន្នាការ អ្នកខុសសីលធម៌ផ្សេងៗ អ្នកជាប់ទីនោះ កន្លែងលត់ដំ ការដ្ឋាន បើសិនលត់ដំមិនបាន សម្លាប់តែម្តង ។ ព័ត៌មានលំអិតមានថតក្នុងកាសែតស្រាប់ ។

ថ្ងៃទី៨-១២-៩៨

ការចុះទៅតាមបណ្តាស្រុកនានា ដើម្បីសិក្សាស្រាវជ្រាវជាក់ស្តែងផ្ទាល់ តាមភូមិ ឃុំនានា និងតាមទីតាំង ឧក្រិដ្ឋកម្ម របស់ស្រុកនីមួយៗ

## I. ស្រុកក្រចេះ

នៅម៉ោង ៨:០០ ថ្ងៃទី៨-១២-៩៨ យើងបានចេញដំណើរពីសាលាខេត្តក្រចេះ តាមផ្លូវជាតិលេខ ......... ឆ្ពោះទៅស្រុកស្នួល ។ នៅសាលាស្រុកយើងបានជួបលោក ៈ

១- លោក **យិន ធីម** អភិបាលស្រុក

២- លោក **សា សន** ប្រធានមន្ទីររដ្ឋបាល សាលាស្រុក

\+ **អំពីព័ត៌មានផ្សេងៗ**

ទីតាំងសាលាស្រុក ឋិតាមដងផ្លូវលេខ៧ នៅក្នុងឃុំអូរឬស្សី ចម្ងាយពីសាលាស្រុក ២គីឡូម៉ែត្រ ។ នៅទិសខាងជើងសាលាខេត្តក្រចេះ ។

+ **ព្រំប្រទល់ស្រុកក្រចេះ**

- ខាងជើង ស្រុកសំបូរ
- ខាងត្បូង ស្រុកឆ្លូង
- ខាងលិច ស្រុកព្រែកប្រសព្វ
- ខាងកើត ស្រុកស្នួល

ស្រុកក្រចេះចែកចេញជា ១៥ឃុំ មាន ៧៨ភូមិ មានប្រជាជន ១៣.៣០៤ គ្រួសារ មានមនុស្ស ៦៩.៦៦៦នាក់ ស្រី ៣៥.៤១៦ នាក់ ។ មុខរបរប្រជាជន ស្រែ និងចំការ តាមដួរមាត់ទន្លេ ។ ផ្ទៃដី សរុប ១.៣៩១ គីឡូម៉ែត្រការ៉េ ។ ផ្ទៃដីកសិកម្ម ៨០៖ ។ ដីទំនេរ ៨៧,៩៨៖ ។ បង្កបង្កើនផល ១០.៣១៧ហិកតា ។ ដីទំនេរ និងលំនៅដ្ឋាន ៦.៣៦៨ ហិចតា ។ DANOSITE ប្រជាជន ៥០នាក់ ក្នុង ១គីឡូម៉ែត្រការ៉េ ។

**អំពីពត៌មានទីតាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍**

១- **គុក សន្តិសុខ** ទីតាំងពិឃាត អូរលង ទីនោះមានការដ្ឋាន លត់ដំ សម្ងាប់តែម្តង ឋិតក្នុងឃុំ ជា ចម្ងាយពីសាលាស្រុក ១០គីឡូម៉ែត្រ ទៅដល់ទីតាំងអូរលង ៥គីឡូម៉ែត្រ សរុប ១៥គីឡូ ម៉ែត្រ សួរមេឃុំឈ្មោះ **កែ សុំ** ។

២- **វិទ្យាល័យព្រះកុសមៈ** ជាគុក និងសន្តិសុខ សម្ងាប់ ទីនោះឋិតក្នុងភូមិត្រពាំងព្រីង ឃុំក្រចេះ ស្រុកក្រចេះ មេឃុំឈ្មោះ **សៅ សារ៉ាក** ។ ទីតាំងនោះជិតសាលាស្រុក (យើងបានមក ចុងក្រោយ) ។

៣- **ក្បាលកោះទ្រង់** ឋិតក្នុងឃុំកោះទ្រង់ នៅកណ្តាលទន្លេមេគង្គ សម្ងាប់ ១០គ្រួសារ (ទីតាំង រលាយដោយទឹកជំនន់) ។

៤- **កោះក្រំ និងកោះស្រការ** ជាទីតាំងសម្ងាប់ ទីនោះឋិតក្នុងឃុំថ្មអណ្តើក នៅកណ្តាលទឹកទន្លេ ចំងាយពីស្រុក ៣០គីឡូម៉ែត្រ (ទៅមិនបាន) គ្មានផ្លូវ ។

៥- **អូសំពោច** ឋិតក្នុងឃុំថ្មី ស្រុកក្រចេះ ទីនោះជាទីតាំងសម្ងាប់ មានការដ្ឋានលត់ដំទីនោះ ទៅ រកជំទប់ **មុំ ខាំ** ចម្ងាយ ៣០គីឡូម៉ែត្រ ពីសាលាស្រុក ផ្លូវលំ លំបាក ព្រៃ (ឡានទៅមិន បានអាចដល់ទៅ ៤០គីឡូម៉ែត្រ ។

ក្រោយពីបានស្រង់ពត៌មានពីអភិបាលស្រុករួច ក្រុមយើងរួម និងប៉ូលីស ១០នាក់ ផង បានធ្វើដំណើរចេញពីសាលាស្រុក តាមផ្លូវលេខ៧ ឆ្ពោះទៅអូរលង ឃុំដា ។

**ក) ទីតាំងគុក និងសន្តិសុខ កន្លែងពិឃាតអូរលង**

ចម្ងាយ ១៥គីឡូម៉ែត្រ ម៉ោង ៨:៤០នាទី យើងបានជួបលោកមេឃុំ **កែ សុំ** នៅទីនោះយើងបានស្រាវជ្រាវរកសាក្សីផ្ទាល់ ដែលធ្លាប់ជាប់គុក ។

នៅទីនោះចែកជា ពីរក្រុម

**ក្រុមទី១** ចុះទៅដល់ទីតាំង ដំណើរថ្មើរជើង ៥គីឡូម៉ែត្រ រួមនឹងប៉ូលីសការពារផង ទីតាំងនោះយើងបានចុះឆ្លេងដៃ ត្រង់ភូមិអញ្ចាញ ដើរកាត់ព្រៃទៅកាន់ទីតាំង ។

**ក្រុមទី២** នៅសាលាឃុំ ជួបយកពត៌មានពីសាក្សី យើងបានយកពត៌មានពីសាក្សី ២នាក់ ម្តាយនិងកូនស្រី ធ្លាប់ជាប់គុកនៅការដ្ឋានអូរលងនោះ ។

សាក្សីទី១ លោកយាយ **ស សយ** អាយុ ៦២ឆ្នាំ នៅភូមិអញ្ចាញ ឃុំដា សព្វថ្ងៃ ជំនាន់ **ប៉ុល ពត** ជាប់គុកនៅអូរលង ។

សាក្សីទី២ អ្នកស្រី **គន់ ពៅ** អាយុ ៤២ឆ្នាំ នៅជាមួយម្តាយ សម័យ **ប៉ុល ពត** កងចល័តអាយុ ១៦ ១៧ឆ្នាំ នាពេលនោះ, គាត់ជាប់រយៈពេល ៣ឆ្នាំ នៅទីនោះ ។

**ពត៌មាន** : នៅទីនោះមានអ្នកជាប់គុកជាច្រើននាក់ទៀតដូចជា :

- **កែ សុទ្ធ** ភូមិអញ្ចាញ (មិននៅ ទៅស្រែចំការ)
- **ជ៉ាន់ ឈាង** មេភូមិអញ្ចាញ មិននៅ ។

ដូច្នេះយើងយកពត៌មាន ពីលោកយាយ **ស សយ** និងមីង **គន់ ពៅ** ជាកូនដូចតទៅ :

**មូលហេតុ** : គាត់ជាប់គុក ប្តីគាត់ជាទាហ៊ានជំនាន់មុន គាត់បានប្រាប់យើងថា ប្រភេទជនរងគ្រោះនៅទីនោះប្រហែលពី ២០០នាក់ ទៅ ៣០០នាក់ ទីតាំងនោះពួកឃាតករ ធ្វើរបងព័ទ្ធ ដោយបង្គោលគ្រាក់ធំៗ រួចដាក់ខ្សែលួស (កូនមាន់ចេញមិនរួចផង) ។ មេឃាតករឈ្មោះ **អារ៉ូ** ។ អ្នកជាប់ទីនោះប្រមូលពីគ្រប់បណ្តាភូមិ ឃុំនានា ទូទាំងស្រុកក្រចេះ ។ មាន ប្រុស ស្រី ក្មេង ចាស់ ឯប្តីៗគេយកទៅកន្លែងផ្សេង កោះស្រការ ។ គាត់ **ស សយ** បានប្រាប់យើងថា ការដ្ឋានអូរលង ឬ គុកអូរលង អ្នកជាប់ទីនោះ គេ អោយលត់ដំការងារធ្វើស្រែ និងចំការ ជីកប្រឡាយទំនប់ ដកស្ទូង កាប់គាស់ ។ល។ បើសិនជាណាលត់ដំ បាន រស់យូរបន្តិច គេអោយធ្វើការទាំងយប់ទាំងថ្ងៃ ហូបបបរាវ ។ ចំពោះ

ស្រីៗក្មេងៗកូនមួយ ពួកឃាត ករឃោរឃៅវាយរំលោភហើយ ទើបសម្លាប់ក្រោយ ជាក់ស្តែងគាត់បានឃើញ គេយកនាងម្នាក់ឈ្មោះ**ផល**កូន១ គេបញ្ឆោតកុហកនាងថា ទៅបើកខោអាវវាយកទៅរំលោភទួលក្បែរនោះ អស់ចិត្ត សម្លាប់ចោល ។ ក្រៅពីនោះ ពួកឃាតករ យកទៅសម្លាប់ ពេលយប់មិនដឹងទីកន្លែងណា គាត់មិន ដឹងដែរ ។ ប៉ុន្តែនៅក្បែរៗ នោះ គាត់បានឃើញខ្លះៗដែរ ក្រោយមកទីនោះមានគេដឹង សូមសួររកឈ្មោះ

**ផន យឿន** ស្រី អាយុ ៥០ឆ្នាំ

**កែវ ខាន់** ប្រុស ជាប្តីប្រពន្ធ

**កែ ហាម** ប្រុស

សព្វថ្ងៃនៅភូមិដា ឃុំដា ។ អ្នកទាំង៣នាក់នោះ ក្រុមយើងមិនបានជួបទេ គេទៅស្រែចំការអស់ហើយ ។

- ចំនួនរណ្តៅគ្មាន (សាក្សីមិនបានបញ្ជាក់)
- ចំនួនអ្នកស្លាប់ ប្រហែល ១០០នាក់
- អ្នកនៅរស់ ប្រហែល ១០០នាក់ ពេលរណសិរ្សរំដោះ ថ្ងៃទី៣០-១២-៧៨ ។

**ខ) ទីតាំងគុក សន្តិសុខ កន្លែងពិឃាត វិទ្យាល័យព្រះកុសមៈ**

ទីតាំងនោះ ជាតំបន់បដិវត្តប្រជាជាតិប្រជាធិបតេយ្យ តាំងពីឆ្នាំ១៩៧០ ទល់ ១៩៧៨-៧៩ ។

ទីតាំងនេះ សម័យ **ប៉ុល ពត** ជាឃ្លាំងគ្រាប់រំសេវផង ។ កន្លែងពិឃាតនៅខាងក្រោយវិទ្យា ល័យ ១០០ម៉ែត្រ នៅទីនោះយើងបានជួប លោក **គីម ជូ** នាយកសាលា លោក **សុខ ស៊ាងម៉េង** នាយករង

- **អំពីពត៌មាន** យើងបានដឹងតាមរយៈលោកនាយក នាយករងវិទ្យាល័យថា ៖

ទីតាំងវិទ្យាល័យព្រះកុសមៈ ជាគុក និងសន្តិសុខពិតប្រាកដ ហើយក៏ជាឃ្លាំងស្តុបអាវុធ គ្រាប់ ខ្មែរក្រហម និងជាមន្ទីរពេទ្យខ្មែរក្រហមដែរ មានអាគារច្រើនណាស់ អាគារខ្លះជាគុក ខ្លះពេទ្យ ខ្លះដាក់ គ្រាប់ ហើយកាលពីឆ្នាំ១៩៧៧-៧៨ មុនខ្មែរក្រហមវារត់ វាចាញ់ ពួកវាបានដុតឃ្លាំងគ្រាប់ ឆេះផ្ទុះ រលំ អាគារ ឃ្លាំងស្តុបគ្រាប់ មុនរណសិរ្សរំដោះ ។

(មានរូបថតតំកល់ទុកសព្វថ្ងៃ នៅសាលានោះ) ។ ចំពោះអាគារ ២ជាន់ មាន ៥បន្ទប់ លើ ៥ ក្រោម ៥ ដាក់អ្នកទោស ជំនាន់នោះ ។

- នៅទីនោះយើងបានស្រាវជ្រាវឃើញសាក្សីដ៏សំខាន់ ឈ្មោះ **សៅ ឃិច** ភេទ ប្រុស អាយុ ៧០ឆ្នាំ គាត់ជាប្រជាជន សម័យ **ប៉ុល ពត** នៅក្បែរវិទ្យាល័យនោះ សព្វថ្ងៃនេះនៅភូមិវត្តប៉ាឆា ឃុំក្រចេះ ស្រុកក្រចេះ ។

គាត់បានអោយក្រុមយើងដឹងថា គាត់នៅទីនេះ ក្បែរសាលានេះតាំងតែពីសម័យ **ប៉ុល ពត** រហូតទល់សព្វថ្ងៃគាត់បានឃើញ បានដឹងថា ទីនោះជាទីតាំងគុក និងសន្តិសុខ ទីតាំងពិឃាត ក្រោយសាលា ១០០ម៉ែត្រ អ៊ីៗឯកភាព របាយការណ៍ នាយកសាលាជំរាបរួច ប៉ុន្តែគាត់បន្ថែមខ្លះៗទៀតថា ៖

- ប្រភេទជនរងគ្រោះ មានពីរជំនាន់ រយៈពេល
- ពី ១៩៧០ ទល់ ១៩៧៥
- ពី ១៩៧៥ ទល់ ១៩៧៩

ពី ១៩៧០ ទល់ ១៩៧៥ ប្រភេទជនរងគ្រោះ

\+ **អ្នកជាប់និន្នាការ** ទាហ៊ាន ប៉ូលីស ពីជំនាន់មុនគេចំរាញ់តាមបណ្តាភូមិ ឃុំនានា ។ ក្នុងពេល នោះកម្មាភិបាលគេជាប់ខ្លះៗដែរ អ្នកខុសសីលធម៌ ស្រីញី ផ្សេងៗ អ្នកគេចោទថា សន្តិសម្ព័ន្ធគឺជាប់នយោ បាយ នៅខាងក្រៅ ទាក់ទិន អ្នកនៅខាងក្នុង ។ ប្រជាជនខ្លះគេចោទថា ជាប់ទាក់ទងខ្មែរស ។

\+ ក្រោយមកទៀត ពី ១៩៧៥ ទល់ ១៩៧៩ អ្នកទោសមន្ត្រីរដ្ឋការ ទាហ៊ាន ប៉ូលីស ពេទ្យ គ្រូ សាស្ត្រាចារ្យ និស្សិត ពួក ១៧ មេសា ដែលជំលៀសពីទីក្រុងនានា ។ ចំរាញ់យកមកដាក់ទីនោះ។ ក្នុងនោះ ក៏មានប្រជាជនមូលដ្ឋានចាស់ខ្លះៗដែរ ប៉ុន្តែតិចទេ ។

ទីតាំងពិឃាត ខាងក្រោយវិទ្យាល័យ ១០០ម៉ែត្រ ទីនោះមាត់បឹង ព្រៃនាម ពួកឃាតករសម្លាប់ពេលយប់ ឯរណ្តៅលប់បាត់អស់ហើយ ព្រៃដុះទ្រុឌ គាត់បានឃើញតែឆ្អឹងក្បាលនៅពាសពេញព្រៃនាមនោះ គាត់ប៉ាន់ស្មានថា អ្នកស្លាប់ ប្រហែលពី ៥០នាក់ ទៅ ១០០នាក់

**ពត៌មានបន្ថែម**

លោកនាយករង បានប្រាប់យើងថា នៅឆ្នាំ១៩៧០ គាត់បានឃើញលោក **ហ៊ូ យន់ ហ៊ូ នឹម ឆឹង អុល** មកផ្សព្វផ្សាយនយោបាយ នៅជាយៗក្រុងក្រចេះ ។ ហើយលោក **អៀង សារី** មកទីរួមខេត្តក្រចេះ ។ គាត់បន្តប្រាប់យើងថា នៅឆ្នាំ១៩៧៨ ពួកនិរតីឡើងមកតំបន់ ៥០៥នេះ ស្រាវជ្រាវរកខ្មែរយៈពាក់ពិននឹងវៀតណាម សម្លាប់ចោលទាំងអស់ ។

ពួកមេៗធំៗនៅទីនោះឈ្មោះ **មិត្តគួន មិត្តយ៉ែម មិត្តយី មិត្តកង** នេះជាគណៈតំបន់ ៥០៥ ។

គណៈតំបន់មកពីនិរតី ក្រោយមកឈ្មោះ **មិត្តប៉ឿន មិត្តខុន** ឯគណៈស្រុក **មិត្តយ៉េង** ។ ពួកនេះមិនដឹងទៅទីណាទេ ។ ឯគណៈតំបន់ ៥០៥ ស្លាប់អស់ ដោយពួកនិរតីមកសម្លាប់ ។

**សេចក្តីសន្និដ្ឋាន**

ស្រុកក្រចេះ ទីតាំងប្រល័យពូជសាសន៍មានច្រើន ប៉ុន្តែយើងចុះបានតែ២ទីតាំងទេ ឯទីតាំងដទៃៗ យើងទៅមិនទាន់បាន មូលហេតុផ្លូវគមនាគមន៍ លំបាក ឆ្ងាយៗ រថយន្តចូលមិនបាន ។ ហើយពេលវេលាតិច ចម្ងាយពីសាលាស្រុកឆ្ងាយៗ ខុសពីបណ្តាស្រុកនានា តំបន់សម្លាប់ច្រើនឆ្ងាយៗ ព្រៃ ហើយក៏គ្មានប្រជាជនរស់នៅទៀតផង ។ ម្យ៉ាងទៀតជនរងគ្រោះស្លាប់ក៏តិចជាងបណ្តាខេត្ត ស្រុកនានា ទូទាំងប្រទេស ការសម្លាប់មិនប្រមូលផ្តុំ ធំដុំ ច្រើនតែចំរាញ់ ហើយសម្លាប់ សម្ងាត់លក្ខការណ៍ ឆ្ងាយៗទៀតផង ។

យើងទាមទារឱកាសក្រោយៗ ផ្លូវងាយស្រួល ស្ថេរភាព សន្តិសុខ យើងនឹងចុះទៅម្តងទៀត លំអិតនៅទីតាំង ដែលយើងមិនទាន់ចុះ ។

## II. ស្រុកសំបូរ

នៅថ្ងៃទី៩-១២-៩៨ ក្រុមស្រាវជ្រាវយើងបានធ្វើដំណើរទៅកាន់សាលាស្រុកសំបូរតាមផ្លូវជាតិលេខ១៣ ក្រចេះ ស្ទឹងត្រែង ។

នៅម៉ោង ៨:៥នាទី យើងបានទៅដល់សាលាស្រុកសំបូរ ជួបអភិបាលស្រុក **ឆុន ទ្រី** និងលោកអភិបាលរង **ព្រៃច សំអឿន** ។

**អំពីពត៌មានផ្សេងៗ**

ក្រោយពីក្រុមស្រាវជ្រាវយើងបានជំរាបអំពីគោលបំនងសំណូមពរ នៃភារកិច្ចយើងរួចមក យើងបានទទួលនូវពត៌មានពីលោកអភិបាលស្រុក ដូចតទៅ :

**ទីតាំងសាលាស្រុកសំបូរ**

សាលាស្រុកសំបូរ ឋិតតាមដងទន្លេមេគង្គ ប៉ែកទិសខាងជើង សាលាខេត្តចម្ងាយពីសាលាខេត្ត ៣៦គីឡូម៉ែត្រ ។ សម័យ **ប៉ុល ពត** ប៉ែកភូមិភាគឥសាន្ត តំបន់ ៥០៥ ។ ជាតំបន់ខ្ពង់រាប និងទន្លេសំបូរទៅដោយព្រៃ ។

**ព្រំប្រទល់ស្រុក**

- ខាងជើង ទល់នឹងខេត្តស្ទឹងត្រែង ស្រុកសៀមបូក
- ខាងត្បូង ទល់នឹងស្រុកក្រចេះ
- ខាងលិច ទល់នឹង(ទន្លេ) និងខេត្តកំពង់ធំ

- ខាងកើត ទល់នឹងខេត្តមណ្ឌលគិរី

ស្រុកនេះចែកជា ១០ឃុំ មាន ៥២ភូមិ ។ ប្រជាជនមាន ៧.៥៨៩ គ្រួសារ មនុស្ស ៤១.២៧២ នាក់ ។ ស្រី ២.១៣៦នាក់ ។ មុខរបរប្រជាជន ធ្វើស្រែ ៨៥៖ ចំការកាប់ឈើ បោកវល្លិ នេសាទត្រី បោក ផ្តៅ ។

ស្ថានការណ៍សន្តិសុខខ្មែរក្រហមគ្មាន មានពួកចាប់ជំរិត ផ្លូវស៊ីងត្រែង ក្រចេះ រយៈកន្លងរួច ។

**ក) អំពីពត៌មានទាក់ទងខុក្រិដ្ឋកម្មប្រល័យពូជសាសន៍ខ្មែរក្រហម សម័យ ៣ឆ្នាំ ៨ខែ ២០ថ្ងៃ**

**១) គុក សន្តិសុខ របស់ស្រុកសំបូរ** សម័យខ្មែរក្រហម ទីនោះឋិតក្នុងឃុំសំបុក ស្រុកសំបូរ ។ ទីតាំងសម្លាប់ក្បែរនោះ មានមួយចំនួន ។ ចម្ងាយពីសាលាស្រុកសំបូរ ១គីឡូម៉ែត្រ ទៅទីតាំងនោះ ។

**២) កោះសំ** ជាការដ្ឋានលត់ដំ ខ្លាំងក្លាបំផុត ជាកោះនៅកណ្តាលទន្លេមេគង្គ ។ ទីតាំងសម្លាប់ចុងកោះសម្លាប់បណ្តែតទឹកចោលតែម្តង មានខ្ទះកប់រណ្តៅ កណ្តាលកោះដែរ ។ ទីនោះឋិតក្នុងភូមិយាវ ឃុំកំពង់ចាម ចម្ងាយពីសាលាស្រុកដល់កោះសំ ៤គីឡូម៉ែត្រ ។ (ទៅមិនបាន ព្រៃ ដើរមិនរួច)

ទីតាំងប្រល័យពូជសាសន៍ឆ្ងាយៗរួមមាន ៖

១- ប្រស្រាល

២- ភ្នំស្រួច

៣- អូរសំពោច

៤- អូរខ្លាំប៉ែរ

៥- អូរចគ្រង់, ពាមអូរចគ្រង់

ទីទាំងអស់ជាការដ្ឋានលត់ដំ (គុកសន្តិសុខ) ផង ។

**បញ្ជាក់** ទីតាំងនេះឆ្ងាយៗ គ្មានផ្លូវ គ្មានប្រជាជនរស់នៅទេសព្វថ្ងៃ ។

១) ត្រចលើ
២) ត្រចក្រោម
ឋិតក្នុងស្រុកក្រចេះ ឯណោះវិញ ជាគុក និងសន្តិសុខដ៏ធំ ។

ទីតាំងនោះ យើងមិនបានទៅទេ នៅស្រុកក្រចេះ ប៉ុន្តែយើងទៅស្រុកក្រចេះមិនបានដឹង (គ្មានរបាយការណ៍) ។

**ទីតាំងគុកសន្តិសុខ សម្លាប់** ឋិតក្នុងឃុំកំពង់ចាម (សំបូរ) ។

**ត្រពាំងដូនអង់** ៦គីឡូម៉ែត្រ ពីសាលាស្រុក ។ ទៅដល់ ឃុំកំពង់ចាម ៤គីឡូម៉ែត្រ ដើរកាត់ព្រៃ ២គីឡូម៉ែត្រ ជិះទូក ៤គីឡូម៉ែត្រ តាមដងទន្លេមេគង្គ ទីតាំងនោះ ។

**មូលហេតុ** ពេលវេលា ដោយព្រៃ (ទៅមិនបាន) ។

ពិបាកធ្វើដំណើរ ផ្លូវលំ ព្រៃ ភក់ និងទឹក ។

ក្រុមយើងសំរេច ចុះទៅតែមួយទីតាំងគឺ ទីតាំងគុក និងសន្តិសុខ កន្លែងសម្លាប់

- គោកក្ដួច ឋិតក្នុងឃុំសំបូរ ចម្ងាយពីសាលាស្រុកសំបូរ ១គីឡូម៉ែត្រ ទៅ ១គីឡូម៉ែត្រកន្លះ ។
- នៅម៉ោង ៩:៣០ ក្រុមយើងមកដល់សាលាឃុំសំបូរ

ជួបមន្ត្រីឃុំ : ១- **អ៊ុច ឃួយ** ស្មៀនឃុំ

២- **សោម ប៊ុនណាន** ជំទប់លេខ២

៣- **រី ឆែម** ជំទប់លេខ៣

៤- **ធួច សំបើម** មន្ត្រីយុត្តិធម៌ស្រុកសំបូរ

នៅសាលាឃុំ មន្ត្រីមូលដ្ឋានបានរកសាក្សីចាំជួបក្រុមស្រាវជ្រាវយើង សាក្សីរួមមាន :

១- **គាំ អ៊ុក** អាយុ ៧៣ឆ្នាំ ធ្លាប់ជាប់គុក គោកក្ដួច សព្វថ្ងៃនៅភូមិចំការក្នុង ឃុំកំពង់ចាម ស្រុកសំបូរ ។

២- **អ៊ុក អៀម** ភូមិកែងប្រាសាទ ឃុំសំបូរ ស្រុកសំបូរ

៣- **នរ សារ៉ែត** ភេទ ប្រុស អាយុ ៥២ឆ្នាំ ធ្លាប់ជាប់គុក គោកក្ដួច ក្រោយមកផ្នែកភស្តុភារដ្ឋានប្រស្រាលគាត់ជាអ្នកយកខ្មោចជនរងគ្រោះនៅប្រស្រាល ដែលខ្មែរក្រហមសំលាប់រួច

**សេចក្ដីបញ្ជាក់**

នៅសាលាឃុំសំបូរចែកជាពីរ ក្រុមស្រាវជ្រាវយើង

- ក្រុមដែនទី ចុះទៅទីតាំងផ្ទាល់ (គោកក្ដួច)
- ក្រុមឯកសារ សំភាសន៍ យកពត៌មាន នៅជួបសាក្សី ឯសាលាឃុំសំបូរ ។

**ការស្រង់យកពត៌មានជាក់ស្តែង** ពីសាក្សីដែលធ្លាប់ជាប់គុក នៅគុក សន្តិសុខ ទីតាំងសម្លាប់ គោកក្ដួចសាក្សីទាំង ៣នាក់ បានអោយយើងដឹងថា : គោកក្ដួច ជាសន្តិសុខ គុក របស់ស្រុកសំបូរ សម័យ **ប៉ុល ពត** កន្លែងសម្លាប់ ក្បែរៗគុកសន្តិសុខនោះ ។

- សាក្សីបានបញ្ជាក់ប្រាប់ថា ក្រៅពីត្រូវសម្លាប់ក្បែរៗគុក ពួកវាបញ្ជូនទៅអូសំពោច ទៅការដ្ឋានប្រស្រាល ទៅលត់ដំទីនោះ យកចេញពីគុក គោកក្ដួច ។

ប្រភេទជនរងគ្រោះរួម ដែលជាប់នៅគោកក្ដួច អ្នកមាននិន្នាការផ្សេងៗ ប៉ូលីស ទាហ៊ាន ប្រជាជន ខុសសីលធម៌ៗ ក្រៅពីនោះកម្មាភិបាលខ្មែរក្រហម ខុសសីលធម៌ ក៏ជាប់នៅទីនោះដែរ ។ សាក្សីបាន បំភ្លឺថា អ្នកជាប់គុកមានខ្នោះដាក់ជើង ដៃ ស៊ីបបរទាំងខ្នោះដៃជើង ។ គ្មានបណ្ដើរ អោយធ្វើការអ្វីទេៗ គាត់បន្ថែម ថា បើដេក ដេកទាំងអស់ បើអង្គុយ អង្គុយទាំងអស់ វេទនាណាស់ គ្មានបានសំរាកអ្វីទេ អ្នក ជាប់គុក គោកក្ដួចនោះ ។

ជនរងគ្រោះជាប់ក្នុងគុក សាក្សីបានអោយដឹងថា ប្រហែលពី ៦០នាក់ ទៅ ១០០នាក់ ។ យក ចេញបញ្ចូលបន្ត្រប់រាល់ថ្ងៃ ខែ រហូតថ្ងៃរំដោះ ។

សាក្សីបញ្ជាក់ថា អ្នកជាប់សន្តិសុខនោះតិចទេ អាចថា ១០០នាក់ ។ អ្នកទាំងនោះគ្មានវាសនា បានរស់ទេ ។ បានរស់តិចបំផុត ។

ចំនួនអ្នកស្លាប់នៅគោកក្ដួច មិនអាចប៉ាន់ស្មានច្បាស់លាស់បានឡើយ ព្រោះគេសម្លាប់មិនអោយ ដឹង ចំពោះសាក្សី **នរ រ៉េត** បានបញ្ជាក់ថា គាត់បានដឹងច្បាស់នៅការដ្ឋានប្រស្រាល ឬ គុកសន្តិសុខ ប្រស្រាល អ្នកស្លាប់ចំនួន ៨៩នាក់ ព្រោះគាត់អ្នកកប់ផ្ទាល់ដៃ គាត់ជាអ្នកភស្តុភា ទទួលខាងកប់ខ្មោច ។

- ទារុណកម្ម នៅសន្តិសុខ រវៃសួរចម្លើយ រាល់ថ្ងៃ ឯនៅប្រស្រាល លត់ដំពលកម្ម ប៉ុន្តែបើនារីៗ ក្មេង ដូចជាកូនមួយ ពួកវារំលោភ រួចបាញ់ចោលតែម្ដង ។

- មេសន្តិសុខ គុក នៅ គោកក្ដួច មាន :

១- **គន់ សារឿន** សព្វថ្ងៃនៅរស់ ភូមិកែងប្រាសាទ ឃុំសំបូរ

២- **នារី គាង** (ប្រពន្ធ) អ្នកសម្លាប់ដូចប្ដីដែរ ។

៣- **មិត្ត ម៉ុន** ប្រពន្ធ **ម៉េត** ប្រពន្ធនៅរស់ (ប្ដីស្លាប់) ប្រធានសន្តិសុខមុន **អ៊ុត សារឿន**

- **មិត្ត អុល** (ងាប់)
- **ហា ម៉េងអាន** នៅភ្នំពេញ
- **មិត្ត មឿ** អ្នកវៃផ្ទាល់ដៃ នៅរស់ភូមិកែងប្រាសាទ ឃុំសំបូរ ស្រុកសំបូរ ។
- **មិត្ត ឱ៉ុយ** អ្នកវៃផ្ទាល់ដៃ នៅរស់ភូមិកែងប្រាសាទ ឃុំសំបូរ ស្រុកសំបូរ ។
- **មិត្ត កៃ យ៉ាប៉ែល** នៅរស់ ភូមិកែងប្រាសាទ ឃុំសំបូរ
- **ធួន សៃ** សន្តិសុខ ស្រុកសំបូរ សម័យខ្មែរក្រហម

- **ឌុក សួរ, ម៉ៅ សែ, អ៊ួច យ៉ឿន, ម៉ន សាមាន និង គន់ ស្រីន** សព្វថ្ងៃនៅភូមិស្រែយឿន ឃុំសំបូរ នៅរស់ទាំងអស់ ។

ក្រុមយើងមានបំណងចង់ទៅជួបពួក ដែលជាមេសន្តិសុខ និងពួកសន្តិសុខ ឬ កម្មាភិបាលសហករខ្មែរក្រហមទាំងអស់នោះដែរ ប៉ុន្តែចៅហ្វាយស្រុក មេឃុំបានប្រាប់យើងថា ពួកគេមិនអោយយើងជួបទេ បានដឹងមុន ឬ បានដឹង គេចមុខ ឬ មិនអោយជួប បើជួបក៏មិនឆ្លើយអ្វី អោយយើងបានដឹងដែរ ។

ក្រុមយើង មានការសង្ស័យថា ហេតុអ្វីក៏ពួកមេសន្តិសុខ ពួកសន្តិសុខ នៅទីនោះរស់ច្រើនម្ល៉េះ? គេថាប្រជាជន ស្រុកសំបូរ ស្លូតបូតណាស់ មិនចេះសងសឹកអ្វីទេ ជាក់ស្តែងលោកតាសាក្សីទី១ គេចាក់គាត់ (**គាំ អ៊ុក** គេចាក់ចំពុះទុងទម្លុះកែងជើងគាត់ គាត់ស្គាល់មុខ អ្នកនោះនៅរស់ក៏គាត់មិនសងសឹកដែរ ។

បញ្ហានេះក្រុមស្រាវជ្រាវយើងខ្ញុំផ្ទាល់ អាចសន្និដ្ឋានថា នៅទីនោះពិតជាមានអាថ៌កំបាំង ឬ មានអ្នកការពារពួកនោះ អាចថា ពួកនោះជាប់ខ្សែជាមួយនរណាមួយ ឬ សាច់ញាតិអ្នកធំជាមន្ត្រីនៅមូលដ្ឋាននោះហើយ ។ ចំពោះការដ្ឋានគុក សន្តិសុខ ចល័ត ប្រស្រាល ពួកដៃដល់ សុទ្ធជនជាតិភាគតិច ភាគតិចទាំងអស់ឈ្មោះ

១- **មិត្តឡាក់** ជនជាតិ ថ្នូន

២- **មិត្តឌី** ជនជាតិថ្នូន

៣- **មិត្តតៀម** ជនជាតិថ្នូន

មេសន្តិសុខឈ្មោះ ១- **អ៊ួន រីម** នៅរស់ភូមិកែងប្រាសាទ ឃុំសំបូរ ។

ទី២ **ឋិន ហឿន** នៅភូមិកែងប្រាសាទ ឃុំសំបូរ អ្នកទាំងនោះនៅរស់ទាំងអស់ ។

- ពួកគណៈស្រុកសម័យ **ប៉ុល ពត** ស្រុកសំបូរ

១- **មិត្ត ឌឿន** ប្រធានស្រុក

២- **មិត្ត ឈូក** អនុប្រធានស្រុក

ពីរនាក់នេះសុទ្ធតែឡើងមកពីនិរតីទាំងអស់ គ្រប់គ្រងស្រុកសំបូរ ។

## សេចក្តីសន្និដ្ឋាន

នៅក្នុងស្រុកសំបូរ គ្រប់ទីតាំងសម្លាប់ យើងបានជួបសាក្សីដែរ ប៉ុន្តែពត៌មានមិនច្បាស់លាស់ដូចទីតាំងខេត្តដទៃៗសោះ ព្រោះពត៌មានយើងបានជួប ហាក់ដូចរាយការណ៍មិនច្បាស់ ពីសាក្សីក្តី មិនដឹងទីតាំងសម្លាប់ គ្មានអ្នកទោស គ្មានអដ្ឋិធាតុ សំគាល់ ហើយទីតាំងសម្លាប់វាឆ្ងាយៗពេក រកសាក្សីរស់នៅ

ក្បែរៗមិនបាន ។ អ្នកជាប់គុកតែផ្ទេរប្តូរ មិនទៅរហូតការពិនិត្យរណ្តៅ មិនបានច្បាស់ ច្រើនសម្លាប់ចោលទំលាក់ទឹក ។

ដូច្នេះការចុះស្រុកសំបូរលើកទី១ នោះលទ្ធផលតិចតួចណាស់ ។ យើងសោកស្តាយណាស់ មន្ត្រីស្រុកក្តី ឃុំក្តី មិនបង្កអោយយើងជួបពួកសន្តិសុខខ្មែរក្រហម យកលេសមិនសមស្របសោះ ថាពួកវាមិនចង់ជួបយើង គេចមុខ មិនឆ្លើយអ្វីប្រាប់យើង ។

យើងគិត បើផ្លូវទីដល់ទីតាំងបានល្អពិសេសរដូវក្តៅ គោក រឹង គ្មានទឹក អាចជិះរទេះគោ កង់ ម៉ូតូ ឬដើរបាន យើងគួរទៅម្តងទៀត ហើយសំខាន់ យើងជួបអោយបានពួកសន្តិសុខដែលនៅរស់ យើងមិនគួរអោយពួកនោះគេចវេស មិនរួមសហការ ជាមួយយើងនោះទេ ។ បញ្ហានេះមន្ត្រីស្រុក ឃុំ មិនទទួលខុសត្រូវ ធ្វើអោយប្រជាជនមានបាត់ដៃ ប្រឡាក់ឈាម ប្រកែកគេចវេសតាមអំពើចិត្ត ។ យើងបានដឹងថាពួកនៅសន្តិសុខ គុកសង់ ទន្លេបាទី តាកែវ ប្រជាជនរដ្ឋអំណាច បង្ខំអោយពួកនោះបារខ្មោចថ្មីៗ នៅស្អុយមិនទាន់រលួយអស់ ឥតប្រកែក ហើយម្យ៉ាងទៀតគេព្រមធ្វើសាក្សី អោយយើងផង ។ ប៉ុន្តែដោយឡែកទេពួកសន្តិសុខខ្មែរក្រហម ស្រុកសំបូរ ប្រកែកធ្វើអ្វីៗតាមចិត្តសោះ ។ ពិចារណា! គួរសាកល្បងម្តងទៀតលើកទី២ទៀត ។

## III. ស្រុកព្រែកប្រសព្វ

នៅថ្ងៃទី៩-១២-៩៨ ក្រុមស្រាវជ្រាវយើងបានបន្តដំណើរចុះទៅស្រាវជ្រាវនៅស្រុកព្រែកប្រសព្វ ម៉ោង៧ យើងបានជិះកាណូតតាមដងទន្លេមេគង្គ ឆ្ពោះទៅស្រុក ទៅដល់សាលាស្រុកនៅម៉ោង ៨:១៥នាទី យើងបានជួប

១- លោក **អ៊ិន ណារម្យ** អភិបាលរងស្រុក

២- លោក **ប៉ាវ ខាន់ថន** អធិការរងស្រុក

**អំពីពត៌មាន**

ទីតាំងសាលាស្រុកឋិតតាមដងទន្លេមេគង្គ នៅប៉ែកទិសនិរតី ចម្ងាយពីសាលាខេត្ត ៨គីឡូម៉ែត្រ ។ ទីតាំងនេះសម័យខ្មែរក្រហម ឋិតនៅភូមិភាគកណ្តាល តំបន់ ២០៣ ប៉ែកខាងលិចទន្លេ គ្រប់គ្រងដោយភូមិភាគកណ្តាល ជាមួយកំពង់ធំ ។

– **ទីតាំងសាលាស្រុកខ្មែរក្រហម**

ឋិតនៅចំទីតាំងសាលាស្រុកព្រែកប្រសព្វ សព្វថ្ងៃនេះ ។

ព្រំប្រទល់ស្រុកសព្ទថ្ងៃ

- ខាងជើង ទល់នឹងស្រុកសំបូរ
- ខាងត្បូង ទល់នឹងស្រុកស្ទឹងត្រែង ខេត្តកំពង់ចាម
- ខាងលិច ទល់នឹងព្រៃរហូតខេត្តកំពង់ធំ
- ខាងកើត ដងទន្លេ ស្រុកឆ្លូង

ស្រុកនេះចែកជា ៨ឃុំ និង ៤៨ភូមិ មានប្រជាជន ១.៨៣៧ គ្រួសារ មានមនុស្ស ៥៤.៧៩១នាក់

មុខរបរប្រជាជនស្រែនិងចំការ កាប់ឈើ បោចវល្លិ៍ ផ្ដៅ នេសាទ។ល។ ជាតំបន់សំបូរព្រៃនិងទន្លេ។

**អំពីពត៌មានទីតាំងប្រល័យពូជសាសន៍ ទូទាំងស្រុកព្រែកប្រសព្វ**

**១) វត្តជ្រោយអំពិល សន្តិសុខ និងគុក +ទីតាំងសម្លាប់**

ទីតាំងសម្លាប់ទម្លាក់អណ្តូងទឹក និងកប់ក្បែរៗនោះ ទីនោះឋិតក្នុងឃុំចំបក់ ស្រុកព្រែកប្រសព្វ ចម្ងាយពីសាលាស្រុក ៣២គីឡូម៉ែត្រ ។

**២) ព្រៃម៉ែសាក់ ខាងមុខសាលាស្រុក**

ទីកន្លែងសម្លាប់ ប្រាំងទន្លេមេគង្គ ទំលាក់ចោលទន្លេ ចម្ងាយពីសាលាស្រុក ១០០ម៉ែត្រ ។

**៣) ទីតាំងអន្លង់ញ៉ោ ទំនប់រំលំញ៉ោ**

ឋិតក្នុងឃុំសោម ចម្ងាយពីសាលា ២៣គីឡូម៉ែត្រ ។ ទីទាំងនោះច្រើនដាក់ពូកថ្មី ១៧ មេសា ចេញពីទីក្រុង

**៤) ភូមិថ្មរាប ឃុំប្រសព្វ**

ទីតាំងសម្លាប់ ទួលក្រសាំង ចម្ងាយ ៥គីឡូម៉ែត្រ ពីសាលាស្រុក ទីតាំងសុទ្ធព្រៃ គ្មានមធ្យោបាយ ព្រៃចង្អៀត ។ ជនរងគ្រោះជាទាហ៊ាន **លន់ ណុល** យកពីចេនឡាទី២ កំពង់ធំ ។ ទីតាំងនោះពីមុន ជំរុំអន្តការបដិវត្តប្រជាជាតិ ពួកខ្មែរក្រហម ។

**៥) ទួលខ្ពង់**

ឋិតក្រោយភូមិព្រែកប្រាំង ឃុំព្រែកប្រសព្វ គេយកពួក ១៧មេសា ទៅដាក់ទីនោះ ទីនោះជាតំបន់គ្រួនចាញ់ មិនបាច់វៃ សម្លាប់ ក៏ស្លាប់ដែរ ។

សព្វថ្ងៃគ្មានប្រជាជនរស់នៅ ព្រៃសុទ្ធសាធ មិនមានផ្លូវទៅបានឡើយ ។

- ក្រោយពីយើងបានស្រង់ព័ត៌មានទីតាំងប្រល័យពូជសាសន៍ យើងបានគិតថា ទីតាំងខ្លះទៅមិន បាន ដូច្នេះយើងសំរេចទៅទីតាំងវត្តជ្រោយអំពិល ទីតាំងនោះឆ្ងាយពិតមែន ប៉ុន្តែអាចទៅដោយមធ្យោ បាយ ផ្លូវទឹកបាន យើងជួលកាណូតរកស៊ីធំមួយ ធ្វើអោយយើងយឺតពេលជាច្រើន ព្រោះយើងចង់ចំណេញ លុយ ... ជាមធ្យោបាយ ។

ធៀតធ្វើដំណើររហូតពីម៉ោង ៨:៣០ ទល់ម៉ោង ១២ ទើបដល់សាលាស្រុកឆ្លូង យើងទៅឈប់ ហូបបាយរួច ជួលអូប័រមួយទៅទីតាំងវត្តជ្រោយអំពិល ចម្ងាយពេល ០,៥០ម៉ោង ។

ប៉ុន្តែឆក់ឱកាសនោះ យើងបានជួបអភិបាលស្រុកឆ្លូង ស្រង់ព័ត៌មានល្អ នូវទីតាំងប្រល័យពូជ សាសន៍ស្រុកឆ្លូង (របាយការណ៍ទំព័រក្រោយ-ខាងមុខ) ។

**ទីតាំងឧក្រិដ្ឋកម្ម**

- **វត្តជ្រោយអំពិល**
- **គុក - សន្តិសុខ**
- **កន្លែងសម្លាប់អណ្តូងទឹកក្នុងវត្ត និងក្បែរៗអណ្តូងទឹក**

ទីវត្តជ្រោយអំពិលឋិតនៅជើងភ្នំសុព័រកាឡី ភ្នំសុព័រកាឡី ប្រវត្តិរឿងព្រេង ជាឈ្មោះក្រពើសុព័រ កាឡី ក្រពើនោះបានខាំប្រយុទ្ធជាមួយក្រពើនាងឱរ៉ៃ ចាញ់ក្រពើនាងឱរ៉ៃ ក្រពើសុព័រកាឡី បានវារមក ងាប់ខ្សាច់មាត់ទន្លេអន្ទង់កាឡី ក្រោយមកក៏ដុះភ្នំមួយឡើង អ្នកស្រុកអោយឈ្មោះថា ភ្នំសុព័រកាឡី រហូត ទល់សព្វថ្ងៃនេះ ។

នៅទីនោះក្រុមយើងបានជួបនឹង :

ព្រះតេជគុណចៅអធិការវត្តព្រះនាម **អ៊ីច សាទុឡ្យ** ព្រះជន្ម ៣២វស្សា បួសពីឆ្នាំ១៩៨៩ ទល់សព្វថ្ងៃ ។ សម័យ **ប៉ុល ពត** កងចល័តនៅភូមិឫស្សីកែវ ស្រុកព្រែកប្រសព្វ ។

១- លោកតា **គៀម យាន** អាយុ ៧៣ឆ្នាំ សព្វថ្ងៃនៅភូមិជ្រោយអំពីល ឃុំចំបក់ ស្រុក ព្រែកប្រសព្វ សម័យ **ប៉ុល ពត** គាត់នៅទីនោះដែរ ។ គឺក្បែរវត្តនោះតែម្តង ក្បែរគុក សន្តិសុខ វត្តជ្រោយអំពិល ។

យើងបានព័ត៌មានសំខាន់ៗ និងជាក់ស្តែង ពីព្រះសង្ឃ និងលោកតា **គៀម យាន** ប្រាប់យើង ថា : ទីតាំងវត្តជ្រោយអំពិល សម័យខ្មែរក្រហមជាគុក និងសន្តិសុខ និងជាកន្លែងសម្លាប់ប្រាកដមែន ព្រះវិ ហារជាកន្លែងស្តុប ឃុំឃាំងមនុស្ស រួចហើយសម្លាប់នៅអណ្តូងទឹក ខាងជើងព្រះវិហារ ។ ឯកុដិថ្មមួយ ទៀត

ក៏ដាក់មនុស្សដែរ ហើយទីនោះកុដិខ្លះទៀត ជាឃ្លាំងសេដ្ឋកិច្ចពួកគេ ។ ហើយក្នុងវត្តនេះជាមន្ទីរ ពេទ្យផងដែរ លុះដល់ឆ្នាំ១៩៧៧-៧៨គេដេញអោយពេទ្យចេញទៅនៅទីតាំងផ្សេង ពេលនោះហើយគេចាប់ផ្តើមសម្លាប់ ។ វិធីសម្លាប់ម្តងៗ គេចាក់បំពងសម្លេងមេក្រូទ្រហឹងអ៊ឹងកង ស្តាប់អ្វីមិនឮសោះឡើយ ។ ព្រមជាមួយនោះគេបិទផ្លូវជាប់វត្តមិនអោយមនុស្សឆ្លងកាត់ទេ ។ (បើនរណាឆ្លង គ្រោះថ្នាក់ស្លាប់) ។ សាក្សីបន្ថែមថាជុំវិញអណ្តូងទឹក មានកប់ខ្មោច អ្នកដេកពេទ្យ ។ ហើយនៅជើងភ្នំមានសម្លាប់ខ្លះដែរ ។

គាត់បានប្រាប់យើងថា ពួកខ្មែរក្រហមបានជីកប្រឡាយរណ្តៅត្រៀមទុកជាច្រើន ជំរៅ១សន្ទូងលេចក្បាល ។ ជាផែនការចុងក្រោយសម្លាប់ទាំងអស់ ប៉ុន្តែត្រូវបានរណសិរ្សសាមគ្គីសង្គ្រោះជាតិរំដោះបានទាន់ពេលវេលា ។ រណ្តៅសម្លាប់គ្មាន សម្លាប់ទំលាក់អណ្តូង អណ្តូងជំរៅ១០ម៉ែត្រ សព្វថ្ងៃនៅឆ្អឹង ពេញ ។

អ្នកស្រុកបានសង់ស្តូបមួយប្រក់ក្បឿង ហើយបានសរសេរចំណងជើងថា :

អណ្តូងឧក្រិដ្ឋកម្ម បនប្រល័យពូជសាសន៍ **ប៉ុល ពត** អក្សរធំៗ ច្បាស់ៗរក្សាបានល្អ ។ សាក្សីបានប៉ាន់ស្មានអ្នកស្លាប់ ពី ១០០នាក់ ទៅ ១៥០នាក់ ទាំងក្នុងអណ្តូង ក្រៅអណ្តូង ។

អំពីប្រភេទជនរងគ្រោះ ដាក់និងសម្លាប់ទីនោះ តាមពុទ្ធដីកាព្រះសង្ឃ និងលោកតាសាក្សីបានអោយយើងដឹងថាៈជនរងគ្រោះជាប់នៅទីនោះច្រើនបំផុតស្ទើរទាំងអស់ប្រជាជនថ្មី ពួក១៧មេសាតែម្តងអ្នកមូលដ្ឋានចាស់តិចតួចទេ។ ហើយច្រើនដឹកប្រមូលពីបណ្តាឃុំនានា មានដឹកមកពីស្រុកស្វឹងត្រង់ខ្លះដែរតាមទូកកាណូត។ អ្នកជំលៀស អ្នកមកស្តុបទីនេះ មិនរៃក្លាមៗទេ ក្រោយមកចំរាញ់ប្រវត្តិរូបរួចទើបសម្លាប់អ្នកចេះលាក់ ប្រវត្តិរូបបានមានរស់ខ្លះដែរ ។ ទីតាំងគុក សន្តិសុខ នេះកសាងពីឆ្នាំ១៩៧០ ទល់ ១៩៧៨ ។ ហើយ ប្រជាជនភាគច្រើនគឺពួក ១៧ មេសា តែម្តងជំលៀសពីទីក្រុង ។ ឯអ្នកមូលដ្ឋានស្លាប់ តិចទេ ។

ឯពួកសន្តិសុខនៅទីនោះ ពួកមកពីនិរតីសម្លាប់អស់ ហើយគ្មានសល់ឡើយ ។ រណសិរ្សរំដោះរួចឆ្នាំ១៩៧៨ ប្រជាជនសង់សឹកអស់ខ្លះទៀត (មិនឃើញនៅរស់ទេសព្វថ្ងៃ) ។

## សេចក្តីសន្និដ្ឋាន

នៅស្រុកព្រែកប្រសព្វ យើងចុះបានតែ១ទីតាំងទេ ព្រោះថា ទីតាំងនេះឆ្ងាយណាស់ យើងធ្វើដំណើរតាមដងទន្លេមេគង្គ ប្រកបដោយគ្រោះថ្នាក់ពេលកំពុងភ្លៀងផង ប៉ុន្តែលទ្ធផលសាក្សីបានបញ្ជាក់ច្បាស់លាស់ ហើយមានភស្តុតាងនៅសេសសល់ទៀតផង ។ ប៉ុន្តែយើងស្តាយមិនបានថតរូបសាក្សី ព្រោះម៉ាស៊ីនថតអស់ហ្វីល ។ ចំពោះទីតាំងដទៃៗទៀត គួរតែយើងចុះស្រាវជ្រាវម្តងទៀត ប៉ុន្តែប្រើរយៈពេលយូរទៅមុខទើបអាចមានផ្លូវទៅបាន ។

## IV. ស្រុកឆ្លូង

ម៉ោង ១២ថ្ងៃត្រង់

ថ្ងៃ៩ ដដែលនោះ យើងឆ្លៀតឱកាសចុះស្រុកព្រែកប្រសព្វផង ស្រុកឆ្លូងផង យើងបានជួបអភិបាលស្រុកឈ្មោះ **ម៉ី រផេង** ទីតាំងស្រុកនោះ ឋិតនៅជងទន្លេមេគង្គដែរ ប្រាំងខាងកើត ចម្ងាយ ៣៦ គីឡូម៉ែត្រ ពីសាលាខេត្ត ។ ឋិតនៅខាងត្បូង ឆៀងខាងកើត ខេត្តក្រចេះ ។

ព្រំប្រទល់ស្រុក

- ខាងលិច   ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម
- ខាងកើត   ស្រុកក្រចេះ
- ខាងជើង   ស្រុកព្រែកប្រសព្វ + ទន្លេមេគង្គ
- ខាងត្បូង   ស្រុកតំបែរ ខេត្តកំពង់ចាម
- ជាតំបន់ខ្ពង់រាប   ព្រៃឈើ
- មុខរបបប្រជាជន ធ្វើស្រែចំការ និងនេសាទ កាប់ឈើ ស្ទឹកទ្រាំង ឫស្សី ។ល។
- ចំនួនប្រជាជន ជាង ៩០០០០នាក់ គ្រួសារជាង ៥០០០គ្រួសារ ។
- ស្រុកនោះមាន ៨ឃុំ និងភូមិ ៤០ភូមិ

### ពត៌មានទីតាំងប្រល័យពូជសាសន៍

១- **គុក សន្តិសុខ ឃុំកញ្ជរ** ទីតាំងសម្លាប់ក្បែរៗនោះ គណៈស្រុកខ្មែរក្រហម នៅទីនោះចម្ងាយ ពីសាលាស្រុក ៧ ទៅ ៨ គីឡូម៉ែត្រ ។

ប្រភេទជនរងគ្រោះ ប្រជាជនថ្មី ពួក ១៧ មេសា អ្នកមូលដ្ឋាន មិនសូវស្លាប់ទេ ។ គេប្រមូលអ្នកខុសឆ្គងពីបណ្ដាឃុំនានាមកដែរ ។

២- **ល្វោក** : ជាការដ្ឋានមន្ទីរកែប្រែ កន្លែងពលកម្មកែប្រែ ។

ឋិតក្នុងឃុំដីរីជុង ចម្ងាយ ៣០គីឡូម៉ែត្រ ពីសាលាស្រុកឆ្លូង ។ ជាការដ្ឋានស្រុកកងចល័ត ជាកន្លែងលត់ដំជាក់ស្តែង ។

៣- **ភ្នំព្រះ** : ចម្ងាយពីសាលាស្រុក ៧គីឡូម៉ែត្រ

សម្លាប់ទំលាក់អណ្តូងទឹក ខ្លះទៀតសម្លាប់វាយប៉ោយ ។ សម្លាប់ឆ្នាំ១៩៧៨ ចំរាញ់ខ្មែរណាយកប្រពន្ធវៀតណាម ឬ វៀតណាមយកប្រពន្ធខ្មែរ សម្លាប់ទាំងអស់ ។

## សេចក្ដីសន្និដ្ឋាន

ការចុះស្រុកឆ្លូង មិនបានទៅដល់ទីតាំងសម្លាប់ទេ គ្រាន់តែបានស្រង់ពត៌មានជាប្រយោលអោយបានដឹង សំរាប់ថ្ងៃខាងមុខ ពេលចុះស្រុកស្នួល យើងចុះស្រុកឆ្លូងម្តងទៀត បើមានឱកាសយើងទៅស្រុកដទៃៗទៀត លំអិតបន្ថែម ពិសេសស្រុកសំបូរ ។

## ការសន្និដ្ឋានរួម

ការចុះលើកទីមួយ ខេត្តក្រចេះនេះ លទ្ធផលបានតិចក៏ពិតមែន ដោយសារទីតាំងស្រុក ទីតាំងប្រល័យពូជសាសន៍ នៅឆ្ងាយៗពេក ។ ប៉ុន្តែយើងបានឃើញស្មារតីសហការមន្ត្រីខេត្ត នគរបាលខេត្ត ស្រុកយកចិត្តទុកដាក់នឹងយើងបានល្អ ដោយឡែកស្រុកសំបូរ លក្ខណៈមន្ត្រីស្រុកខ្សោយខាងបង្កការងាយស្រួលដល់ក្រុមយើង ។

ម្យ៉ាងទៀត ចំពោះក្រុមយើងវិញមានចំណុចគួរអោយសោកស្តាយ ចំពោះការឧបត្ថម្ភជូនអ្នកនាំ ផ្លូវមន្ត្រីប្រធានពត៌មានខេត្ត រយៈ៣ថ្ងៃ អ្នកបើកបររថយន្ត យើងអត់បានជូនឧបត្ថម្ភលើកទឹកចិត្តគេសោះ យើងបានអោយការហូបចុកសមរម្យមែន ប៉ុន្តែទង្វើរនេះនៅខ្វះខាតនៅឡើយ មិនជាការងាយស្រួលទៅពេលខាងមុខប៉ុន្មានឡើយ នេះតាមទស្សនៈចិត្តសាស្ត្រដែលយើងស្ទាបស្ទង់អ្នករួមដំណើរផ្នែករថយន្ត និងមន្ត្រីខេត្ត ។ ទោះបីជាយ៉ាងណាក៏ដោយ ត្រូវតែមាន ទោះតិចក្តី មិនអាចខ្វះបានឡើយ ។ សំណូមពរពិចារណា ។

ភ្នំពេញ,ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩៨

អ្នកសរុបរបាយការណ៍ជាក់ស្តែង

**ស៊ិន យិន**

- ពីមន្ទីរស្រុកដល់គុកគោកក្តួចប្រហែល ៤គីឡូម៉ែត្រ
- ចុះពីផ្លូវលំទៅដល់គុកគោកក្តួចប្រហែល ២គីឡូម៉ែត្រ






- ពីរង្វង់មូលដល់មន្ទីរស្រុក ប្រហែល ២គីឡូម៉ែត្រ
- ពីរង្វង់មូលខេត្ត ដល់មន្ទីរឃុំដា ១៣គីឡូម៉ែត្រ